# លេខចេញផ្សាយទី៥ ខែកក្កដា ឆ្នាំ២០២០

**មាតិកា**


1. ទស្សនៈរបស់ដៃគូចំពោះគម្រោងTIGER៖ អង្គការសកម្មភាពកុមារដើម្បីអភិវឌ្ឍន៍
2. រឿងអប់រំថ្មីៗត្រូវបានចេញផ្សាយដោយប្រើកម្មវិធីរឿងអប់រំប្រកបដោយអន្តរកម្ម!
3. ថ្លែងអំណរគុណចំពោះម្ចាស់ជំនួយ!
4. ព័ត៌មានទំនាក់ទំនង


TIGER
លើកកម្ពស់ការឆ្លើយតបនឹងសមភាពយេនឌ័រក្នុងការបង្រៀន និង រៀន
TEACHING FOR IMPROVED GENDER EQUALITY AND RESPONSIVENESS

## ទស្សនៈរបស់ដៃគូចំពោះគម្រោងTIGER៖ សកម្មភាពកុមារសម្រាប់ការអភិវឌ្ឍន៍



សូមណែនាំឱ្យស្គាល់លោកស្រី ម៉ៅ ស៊ីដាណា នាយករងសាលាបឋមសិក្សា ព្រៃកន្ទោរក្នុងខេត្តបាត់ដំបង។ ចាប់តាំងពីខែវិច្ឆិកា ឆ្នាំ២០១៨ គាត់បានចូលរួមជាមួយ អង្គការសកម្មភាពកុមារដើម្បីអភិវឌ្ឍន៍ (CAD) ដែលជាដៃគូរបស់គម្រោង TIGER។ CAD ជាអង្គការមួយក្នុងចំណោមអង្គការសង្គមស៊ីវិលទាំង៥ ដែលទទួលបានការកសាងសមត្ថភាពរយៈពេល២ឆ្នាំអំពីគម្រោងលើកកម្ពស់ការឆ្លើយតបនឹងសមភាពយេនឌ័រក្នុងការបង្រៀន និងរៀន (TIGER) ដែលអនុវត្តដោយអង្គការ VVOB, KAPE និង PKO។ គម្រោងនេះបានផ្តល់ជំនួយថវិកាដល់អង្គការសង្គមស៊ីវិលនីមួយៗរៀបចំសកម្មភាពបំប៉ននៅសាលាបឋមសិក្សា និងអនុវិទ្យាល័យចំនួន២០។ សាលាបឋមសិក្សាព្រៃកន្ទោរ ជាសាលាមួយក្នុងចំណោមសាលាទាំង២០នោះ។

ពោរពេញដោយមោទនភាព គាត់បានចែករំលែកបទពិសោធន៍អំពីគម្រោង TIGER ថា៖ "បុគ្គលិកអង្គការ CAD សម្របសម្រួលសិក្ខាសាលាអំពីការបង្រៀន និងរៀន និងការដឹកនាំសាលារៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រ។ នេះជាវគ្គបំប៉នមួយដ៏គួរឱ្យចាប់អារម្មណ៍ ផ្តោតលើការផ្លាស់ប្តូរជាវិជ្ជមានក្នុងការអនុវត្តគោលវិធីឆ្លើយតបនឹងសមភាពយេនឌ័រនៅក្នុងសាលារៀនរបស់យើង។ ខ្ញុំកោតសរសើរចំពោះវិធីសាស្រ្តដ៏មានប្រសិទ្ធភាពដែលត្រូវបានប្រើនៅក្នុងវគ្គបំប៉ននោះ។ វិធីទាំងនោះជួយឱ្យខ្ញុំងាយស្រួលនឹងអនុវត្តចំណេះដឹង និងជំនាញដែលខ្ញុំទទួលបាននៅក្នុងសាលារៀនរបស់យើង។ ដោយសារសាលារៀនយើងមានបញ្ហាប្រឈមក្នុងការកែប្រែការអនុវត្ត អង្គការ CAD បានលើកសំណើវគ្គបំប៉នមួយផ្សេងទៀតសម្រាប់គ្រូទាំងអស់គ្នានៅក្នុងសាលារៀនរបស់យើង។ នៅក្នុងវគ្គបំប៉ននេះ គ្រូរបស់យើងរៀនចេះវិធីបង្រៀន និងរៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រ និងរៀបចំផែនការដើម្បីបញ្ចូលភាពឆ្លើយតបនឹងសមភាពយេនឌ័រទៅក្នុងការបង្រៀនរបស់គាត់។ លោកគ្រូ អ្នកគ្រូនឹងបញ្ចូលសកម្មភាពបង្រៀនផ្អែកលើយេនឌ័រទៅក្នុងកិច្ចតែងការបង្រៀន ដំណើរការកសាងសម្ភារឧបទេស សកម្មភាព និងគោលការណ៍ថ្នាក់រៀនដើម្បីធានាបាននូវមជ្ឈដ្ឋានមួយដែលមានសុវត្ថិភាព និងអំណោយផលដល់ការរៀនសូត្រ"។

អង្គការ CAD ក៏ផ្តល់ការបង្វឹកផ្ទាល់ជាលក្ខណៈបុគ្គលនៅក្នុងសាលារៀនផងដែរ ដើម្បីជំរុញលំនាំប្រែក្លាយសាលារៀនឱ្យមានលក្ខណៈឆ្លើយតបនឹងសមភាពយេនឌ័រ ផ្អែកលើខ្លឹមសាររបស់ឯកសារណែនាំរបស់គម្រោង TIGER។ ផ្នែកមួយដ៏សំខាន់នៅក្នុងឯកសារនោះផ្តោតលើការចូលរួមរបស់មាតាបិតា និងសហគមន៍។ មាតាបិតា និងសហគមន៍អាចដើរតួនាទីសំខាន់ក្នុងការលើកកម្ពស់សមធម៌យេនឌ័រ និងកសាងភាពរឹងមាំរបស់កុមារដើម្បីផ្លាស់ប្តូរផ្នត់គំនិតយេនឌ័រដែលពិបាកកែប្រែ។ ពេលដែលសាលារៀនមានលក្ខណៈឆ្លើយតបនឹងសមភាពយេនឌ័រ គេចាំបាច់ត្រូវមានការគាំទ្រពីមាតាបិតា។ "យើងចាប់ផ្តើមសម្គាល់ឃើញថាមានមាតាបិតា និងសមាជិកសហគមន៍កាន់តែច្រើនឡើងដែលទំនាក់ទំនងជាមួយគ្រូ និងសាលារៀន។ ខ្ញុំជឿជាក់ថា ទំនាក់ទំនងល្អគឺជាជំហានដំបូងដ៏សំខាន់ដើម្បីសាងទំនាក់ទំនងដ៏រឹងមាំជាមួយមាតាបិតា និងសហគមន៍ដែលនៅជុំវិញសាលារៀនរបស់យើង។ សាលារៀនមិនមែនជារបស់នរណាម្នាក់នោះទេ គឺជារបស់អ្នកទាំងអស់គ្នា ដូច្នេះហើយទើបចាំបាច់ត្រូវមានការចូលរួមរបស់សហគមន៍"។

ការគាំទ្ររបស់ អង្គការ CAD ត្រូវបានវាយតម្លៃខ្ពស់។ លោកស្រីម៉ៅ ស៊ីដាណាបានសង្កត់ធ្ងន់ថាគម្រោង TIGER បានជួយឱ្យ ពួកគាត់មានឱកាសបានរៀនសូត្រពីគ្នាទៅវិញទៅមក និងពង្រឹងភាពអង់អាចរបស់គណៈគ្រប់គ្រង និងគ្រូបង្រៀនដើម្បីឱ្យមានភាពរីកចម្រើន។ "យើងចាំបាច់ត្រូវមើលឃើញបញ្ហាប្រឈមដែលនៅសេសសល់ និងស្វែងរកដំណោះស្រាយចំពោះបញ្ហាទាំងនេះដោយខ្លួនឯង។ ខ្ញុំជឿជាក់ថា ពេលដែលមានអ្នកចូលរួមសហការកាន់តែច្រើន យើងអាចបង្កើតឱ្យបានការផ្លាស់ប្តូរកាន់តែច្រើនទៅតាមនោះដែរ។ អង្គការ CAD ពិតជាបានជួយដល់សាលារៀន គ្រូបង្រៀន និងសហគមន៍តាមរយៈគម្រោង TIGER ដែលរួមសហការគាំទ្រថវិកាដោយសហភាពអឺរ៉ុប និងរដ្ឋាភិបាលប្រទេសប៊ែលហ្ស៊ិក"។

## ការចេញផ្សាយរឿងថ្មីនៅក្នុងកម្មវិធីរឿងអប់រំប្រកបដោយអន្តរកម្ម



*ក្មេងប្រុសម្នាក់ឈ្មោះ ប៊ុនណា មានអារម្មណ៍មិនស្រួលពេលនៅសាលារៀន ព្រោះគ្រូរបស់គាត់ធ្វើចំពោះសិស្សមិនស្មើគ្នា ដោយផ្អែកលើភេទរបស់ពួកគេ។ បើអ្នកជាប៊ុនណាវិញ តើអ្នកនឹងធ្វើដូចម្ដេច?*



*ពេលចេញលេង ក្មេងស្រីម្នាក់ឈ្មោះ សុខា បានឃើញក្មេងប្រុសៗលេងបាល់ទាត់ ហើយនាងក៏សម្រេចចិត្តថាលេងជាមួយគេដែរ។ តើអ្នកយល់ដូចម្ដេចចំពោះក្មេងស្រីដែលលេងបាល់ទាត់?*



*មានថ្ងៃមួយ មិត្តរួមថ្នាក់របស់ មាលា បង្ហាញនាងនូវរូបភាពអាសអាភាសមួយ។ នាងមានអារម្មណ៍ថាអាក់អន់ចិត្តខ្លាំងណាស់។ តើ មាលា គួរធ្វើដូចម្ដេច? តើគ្រូរបស់នាង គណៈគ្រប់គ្រងសាលារៀន និងឪពុកម្ដាយរបស់របស់នាងគួរឆ្លើយតបចំពោះរឿងនេះយ៉ាងដូចម្ដេច?*

តើអ្នកនឹងធ្វើដូចម្ដេច បើអ្នកជា មាលា ប៊ុនណា ឬសុខា? ពេលអាន និងស្ដាប់រឿងនិទានទាំងនេះ អ្នកអាចសរសេរអត្ថបទដើម្បីបញ្ជាតួអង្គ និងជះឥទ្ធិពលលើមជ្ឈដ្ឋានរឿង។ នេះជារបៀបដែលអ្នកអាចទទួលអារម្មណ៍អំពីលទ្ធផលនៃការជ្រើសរើសរបស់អ្នក។

កម្មវិធីរឿងអប់រំប្រកបដោយអន្តរកម្មគឺជាបណ្ណាល័យឌីជីថលដែលមានរឿងនិទានសម្រាប់គ្រូ សិស្ស ឪពុកម្ដាយ និងសហគមន៍។ ជារឿងនិទានដែលជាប់ទាក់ទងនឹងជីវភាពរស់នៅជាក់ស្ដែង ដែលសមភាព (ឬវិសមភាពយេនឌ័រ) ឬការបង្កើតផ្នត់គំនិតកើតមាននៅក្នុងសាលារៀន និងនៅក្នុងសហគមន៍។

តើអ្នកចង់ដឹងទេ? សូមទាញយកកម្មវិធីរឿងអប់រំតាមរយៈតំណភ្ជាប់ https://bit.ly/TIGER-app

## ថ្លែងអំណរគុណចំពោះម្ចាស់ជំនួយ!

THIS PROJECT IS CO-FUNDED BY THE EUROPEAN UNION

Belgium partner in development

Flanders State of the Art

**#B-53, Borey Pea Nechakam CANADIA,**
**Kamakor, Svaypor, Battambang, Cambodia**
**Cambodia.vvob.be/tiger**
**Find us on Facebook: @vvobcambodia**
**@kapeaction, and @pkocambodia.org**

*This newsletter was produced with the financial support of the European Union. Its contents are the sole responsibility of VVOB, KAPE, and PKO and do not necessarily reflect the view of the European Union. The Belgian and Flemish governments cannot be held responsible for its content.*